**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជារំលឹកលោកប៉ូយៀបនៅផ្លូវត្រី**
**ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៨**
*កែប្រែចិត្តគំនិតត្រលប់ទៅរកព្រះជាម្ចាស់វិញ*

អត្ថបទទី១៖ ២របា ៣៦,១៤-១៦.១៩-២៣
អត្ថបទទី២៖ អភ២,៤-១០
ដំណឹងល្អ៖ យហ ៣,១៤-២១

បងប្អូនជាទីស្រឡាញ់!

បងប្អូនដែលមកច្រើន តាមពិតយើងស្គាល់លោកយៀប ដោយសារតាមអ្វីដែលគេនិយាយតៗគ្នា លោកយៀបបានជួយយើងឲ្យយើងរកស៊ីបានច្រើន។ លោកយៀប ដែលបានទទួលព្រះវិហារនៅទីនេះនៅឆ្នាំ១៩២៤ គាត់បានបម្រើព្រះសហគមន៍អស់ពីដួងចិត្តអស់ពីជំនឿរបស់គាត់។ ហេតុនេះហើយ ថ្ងៃនេះយើងអាចនិយាយថា "អបអរសាទរបុណ្យនៃសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់"។

ថ្ងៃនេះ យើងបានស្ដាប់យ៉ាងជាក់ស្ដែង យ៉ាងច្បាស់លាស់នៅក្នុងព្រះគម្ពីរដំណឹងល្អ "**ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ហេតុនេះហើយបានជាព្រះជាម្ចាស់ប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គមក**"។ ថ្ងៃនេះ យើងស្ដាប់ដំណឹងល្អដល់កំពូលនៃជីវិតរបស់យើងជាគ្រីស្ដបរិស័ទ ដែលណែនាំឲ្យយើងជួបជុំគ្នារៀងរាល់ថ្ងៃអាទិត្យ ដែលណែនាំឲ្យមនុស្សមកថ្ងៃនេះរាប់ពាន់នាក់។ ព្រះជាម្ចាស់ ស្រឡាញ់មនុស្សលោកខ្លាំងណាស់ មានន័យថាព្រះជាម្ចាស់ស្រលាញ់យើងខ្លាំងណាស់។ ហេតុនេះហើយ ព្រះជាម្ចាស់បានណែនាំឲ្យព្រះបុត្រាយាងមក ដើម្បីឲ្យយើងមានជីវិត។ ថ្ងៃនេះ ជាសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ដែលយើងមើលឃើញជាក់ស្ដែង តាមរយៈលោកយៀបដែលបម្រើព្រះសហគមន៍រហូតដល់បាត់បង់ជីវិត។ ថ្ងៃនេះ ជាសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ដែលណែនាំឲ្យយើងជួបជុំគ្នា ដើម្បីអរព្រះគុណព្រះជាម្ចាស់។ ឱព្រះបិតាអើយ! ព្រះអង្គស្រឡាញ់ខ្ញុំណាស់ ហេតុនេះហើយ ថ្ងៃនេះយើងខ្ញុំចង់អរព្រះគុណព្រះអង្គអស់ពីដួងចិត្ត ព្រះអង្គដែលណែនាំឲ្យមានព្រះបុត្រាយាងមកសង្គ្រោះយើងខ្ញុំ។ សូមមើលឃើញព្រះយេស៊ូ ២០០០ឆ្នាំមុនពេលព្រះយេស៊ូយាងពីភូមិមួយទៅភូមិមួយ មានមហាជនដូចថ្ងៃនេះដើម្បីជួបជុំគ្នា ដើម្បីប៉ះព្រះយេស៊ូ ដើម្បីស្ដាប់ព្រះបន្ទូលរបស់ព្រះអង្គ ដោយសារមនុស្សយើងកំពុងស្រេកឃ្លានសេចក្ដីស្រឡាញ់ដែលមកពីព្រះបិតាផ្ទាល់។ អ្នកដែលមកជួបព្រះយេស៊ូ មហាជនដែលមក

ជួបព្រះយេស៊ូ គឺអ្នកក្រីក្រ អ្នកដែលគ្មានទីពឹង ស្ត្រីដែលគេមើលងាយ ជាអ្នកជំងឺ ជនពិការ អ្នកដែលអស់សង្ឃឹម។ គេមកច្រើនដើម្បីស្តាប់ព្រះយេស៊ូ ដើម្បីស្គាល់ព្រះយេស៊ូ ជាអ្នកមានបាបដែលមកស្តាប់ព្រះយេស៊ូពីសម័យព្រះយេស៊ូ២០០០ឆ្នាំមុន។ បងប្អូនជាទីស្រឡាញ់! ខ្ញុំជឿថា ថ្ងៃនេះយើងក៏ឃើញដូចគ្នាដែរ។ យើងជាអ្នកក្រីក្រ យើងជាអ្នកជំងឺ យើងជាអ្នកមានបាប យើងជាអ្នកដែលគ្មានទីពឹង យើងជាអ្នកដែលពិបាកក្នុងចិត្ត និងថ្ងៃនេះយើងមកដើម្បីជួបព្រះយេស៊ូ។

មូលហេតុ ដែលយើងមកជួបព្រះយេស៊ូ ដើម្បីស្តាប់ព្រះបន្ទូលគឺ "**ព្រះជាម្ចាស់បានចាត់ព្រះបុត្រារបស់ព្រះអង្គឲ្យយាងមកក្នុងលោកនេះ មិនមែនដើម្បីដាក់ទោសដល់មនុស្សលោកទេ ប៉ុន្តែដើម្បីសង្គ្រោះឲ្យមនុស្សលោកមានជីវិត**"។ ព្រះយេស៊ូយាងមកដោយមានព្រះបន្ទូលថា "**បងប្អូនអើយ! បងប្អូនជាអ្នកមានបាប ប៉ុន្តែសូមកែប្រែចិត្តគំនិតទៅ!**" កែប្រែចិត្តគំនិតដើម្បីត្រលប់ទៅព្រះជាម្ចាស់វិញ។ ម្សិលមិញយើងអធិដ្ឋាន២៤ម៉ោង ដើម្បីទូលសូមឲ្យមនុស្សទាំងអស់កែប្រែចិត្តគំនិតត្រលប់ទៅព្រះជាម្ចាស់វិញ។ បុណ្យដែលយើងគោរពលោកយៀបនៅថ្ងៃនេះ ជាឱកាសមួយដើម្បីត្រលប់ទៅរកព្រះជាម្ចាស់វិញ ដើម្បីស្វែងរកឃើញទ្រព្យសម្បត្តិពិតៗនៅក្នុងដួងចិត្តរបស់យើង។ ទ្រព្យសម្បត្តិពិតៗរបស់យើង មិនមែនដូចយើងធ្លាប់ឮក្រុមគ្រួសារថា ប្តីស្រឡាញ់មាស ប្រពន្ធស្រឡាញ់លុយ និងធ្វើដំណើរជាមួយគ្នាដើម្បីរកស៊ីពីព្រឹកដល់យប់ និងពីយប់ដល់ព្រឹក ដោយមិនដែលមានពេលមើលគ្នាទៅវិញទៅមកជាប្តីប្រពន្ធ។ អត់ដែលមានពេលដើម្បីថែក្សាកូនៗ ដោយសារប្តីដើរតាមមាស ប្រពន្ធដើរតាមលុយ។ ហេតុនេះហើយ ថ្ងៃនេះយើងមិនមកដើម្បីរកស៊ីតាមប្រាក់និងមាស។ ថ្ងៃនេះ យើងមកដើម្បីរកស៊ីទ្រព្យសម្បត្តិរបស់ព្រះជាម្ចាស់ គឺសេចក្តីស្រឡាញ់ដ៏អស្ចារ្យដែលព្រះអង្គប្រទានឲ្យយើង។

បងប្អូនជាទីស្រឡាញ់!

លោកសិលា ដែលនិយាយទៅអ្នកក្រីក្រម្នាក់ អ្នកជំងឺម្នាក់ដែលសុំលុយពីគាត់ គាត់បានឆ្លើយថា "**ខ្ញុំគ្មានប្រាក់ ខ្ញុំគ្មានមាស ប៉ុន្តែអ្វីដែលខ្ញុំមាន ខ្ញុំឲ្យក្នុងព្រះនាមព្រះយេស៊ូគ្រីស្តសូមឈរឡើងហើយទៅចុះ!**"។ ដូច្នេះថ្ងៃនេះ បងប្អូនសូមបើកត្រចៀកឲ្យធំបំផុត ដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ។ ថ្ងៃនេះ ព្រះយេស៊ូអត់មានប្រាក់ អត់មានមាសដើម្បីប្រទានឲ្យ

យើង ប៉ុន្តែព្រះយេស៊ូមានទ្រព្យសម្បត្តិដែលមានតម្លៃលើសទ្រព្យសម្បត្តិទាំងឡាយ។ ព្រះយេស៊ូប្រទានសេចក្តីស្រឡាញ់ និងជីវិត ព្រះយេស៊ូប្រទានសេរីភាពដើម្បីឲ្យយើងទៅជាមនុស្សពេញលក្ខណៈដ៏មានតម្លៃដល់កំពូល។ នៅក្នុងរដូវ៤០ថ្ងៃ ដែលជារដូវយើងមើលឃើញភាពងងឹតនៅក្នុងជីវិតរបស់យើង។ ថ្ងៃនេះ យើងទទួលស្វាគមន៍ពន្លឺនៃពិភពលោក ព្រះយេស៊ូ ជាពន្លឺនៃពិភពលោកដើម្បីមកបំភ្លឺភាពងងឹតរបស់យើង។ យើងដឹងហើយពេលយើងធ្វើអ្វីខុស ពេលយើងធ្វើអំពើឃោឃៅខុសធម្មវិន័យរបស់ព្រះយេស៊ូ យើងចូលចិត្តបិទភ្លើង យើងចូលចិត្តស្ងាត់ៗនៅក្នុងភាពងងឹតនៃជីវិតរបស់យើង។ ប៉ុន្តែថ្ងៃនេះមានភ្លើងអំពូលហ្វាមួយយ៉ាងធំណាស់ ដែលមកបំភ្លឺជីវិតរបស់យើងទាំងអស់ ដើម្បីរកឃើញភាពងងឹតរបស់មនុស្សយើងទាំងអស់ ដើម្បីឲ្យយើងទៅជាមនុស្សថ្មី ដោយសារព្រះយេស៊ូមិនយាងមកមិនមែនដើម្បីកាត់ក្តី ដើម្បីដាក់ទោសឲ្យយើង តែយាងមកដើម្បីឲ្យមនុស្សមានជីវិត។

ដូច្នេះថ្ងៃនេះ ខ្ញុំអញ្ជើញបងប្អូន ពេលអភិបូជាហើយសូមអធិដ្ឋានថែមទៀត ដូចយើងបានស្តាប់ "**យើងជាស្នាព្រះហស្ត ដែលព្រះជាម្ចាស់បានបង្កើតមកក្នុងអង្គព្រះយេស៊ូ ដើម្បីឲ្យយើងប្រព្រឹត្តអំពើល្អ ដែលព្រះអង្គបានបម្រុងទុកជាមុនសម្រាប់យើងខ្ញុំដើរតាម**"។ ថ្ងៃនេះយើងអធិដ្ឋានហើយអធិដ្ឋានទៀត ដើម្បីឲ្យយើងរៀងៗខ្លួនប្រព្រឹត្តអំពើល្អតាមព្រះបន្ទូលរបស់ព្រះយេស៊ូ។ អ្វីដែលសំខាន់ថ្ងៃនេះ ឲ្យយើងមានលេខឆ្នោតរបស់ព្រះជាម្ចាស់ដែលណែនាំយើងពេលទៅវិញ អាចជាប់លេខអស្ចារ្យរបស់ព្រះអង្គ គឺលេខដែលណែនាំឲ្យយើងពោរពេញដោយសេចក្តីស្រឡាញ់ ដើម្បីចែករំលែកសេចក្តីស្រឡាញ់ដល់បងប្អូនឯទៀតៗ។ ថ្ងៃនេះ សំខាន់ណាស់ក្នុងការរើសលេខរបស់ព្រះជាម្ចាស់ ដែលណែនាំឲ្យយើងពេលនេះមានកម្លាំងនៅក្នុងខ្លួន ដោយដឹងថាថ្ងៃនេះខ្ញុំបានទទួលកម្លាំងថ្មីមែន។ ថ្ងៃនេះ ខ្ញុំចង់ទៅជាឪពុកមួយល្អជាងមុន ប្រពន្ធមួយល្អជាងមុន ម្តាយល្អជាងមុន ទៅជាកូនល្អជាងមុន ជាយាយល្អជាងមុន ទៅជាអ្នកជិតខាងល្អជាងមុន....។ល។ ដើម្បីបម្រើព្រះសហគមន៍ ដូចលោកយៀបបានបម្រើព្រះសហគមន៍ដែរ។

ដូច្នេះបងប្អូនជាទីស្រឡាញ់! ថ្ងៃនេះពិតមែនយើងពោរពេញដោយកម្លាំង សូមឲ្យយើងត្រលប់ទៅរកព្រះជាម្ចាស់វិញ ដើម្បីទទួលសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ សូមឲ្យយើងរស់នៅក្នុងពន្លឺ ដែលណែនាំឲ្យយើងទៅជាមនុស្សដែលឈរឡើង ដើម្បីប្រកាស

សេចក្តីស្រឡាញ់របស់ព្រះអង្គតាមរយៈជីវិតរបស់យើងជាប្រចាំ ដើម្បីប្រព្រឹត្តអំពើល្អតាមព្រះយេស៊ូ។

ហេតុនេះហើយ ថ្ងៃនេះយើងអរព្រះគុណព្រះជាម្ចាស់ យើងអបអរសាទរបុណ្យរកព្រះបន្ទូលរបស់ព្រះអង្គជាទ្រព្យសម្បត្តិ។ យើងសូមព្រះអង្គប្រទានពរឲ្យយើងទាំងអស់ ជាក្រុមគ្រួសារ ជាគ្រីស្តបរិស័ទ ដើម្បីឲ្យជីវិតរបស់យើងភ្ជាប់យ៉ាងជិតស្និទ្ធជាមួយព្រះជាម្ចាស់។ អាម៉ែន៕

**ជយោ! ព្រះជាម្ចាស់ដែលស្រឡាញ់យើងខ្លាំងណាស់!**